**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
**-លេខ ១០៥ "ជ" ក្រ.៣**
**-ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣**
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៤៨២
ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ: ៣៤៥៦
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ: ៤៥០៩
ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៨និង៣០នាទី នៅបន្ទប់សវនាការទី ២ នៃសាលាដំបូងរាជធានីភ្នំពេញ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៨២ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ហៅ **អាធី** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ០៧ ផ្លូវបេតុង ក្រុមទី១ ភូមិព្រៃគី សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **សំណាង** "**រ**" ម្តាយឈ្មោះ [redacted] **ស្រីស៊ីម** "**រ**" នៅលីវ ជាទីតិជន ទោសពីមុន **គ្មាន** ។

**-មានខ្លួន:** ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **៩៨៥៣ "ជ"ង.ឃ.ង** ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៧** នៃ **ក្រមព្រហ្មទណ្ឌ** ។

-ដោយមានមេធាវី [redacted] មានការិយាល័យផ្ទះលេខ៣៣អា ជាន់ទី២ ផ្លូវលេខ១៨៣ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ដោយមានមេធាវី [redacted] មានការិយាល័យផ្ទះលេខ១២៣ ផ្លូវលេខ១៣៦ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ដោយមានមេធាវី [redacted] មានការិយាល័យផ្ទះលេខ៣៥AE0E1E2 ផ្លូវលេខលំ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ដោយមានមេធាវី [redacted] មានការិយាល័យភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ភស្ស ភេទស្រី អាយុ៥៨ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ V២៣ ភូមិព្រៃសំព័រ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍សំយោគលេខ ០១៨/២២ រ.ប.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ។

-បានឃើញដីកាបញ្ជូនសំណុំរឿងឱ្យស៊ើបសួរលេខ **៣៣៩៦** អ.យ.**ជ** ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ **៤២៩៥** អ.យ.**ជ** ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ **៥៧៤៨ "ជ"ង.ង** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុដែលបណ្តាលឲ្យមានការចោទប្រកាន់មានដូចតទៅ

-តាមដីកាសន្និដ្ឋានស្ថាពរលេខ **៤២៩៥** អ.យ.**ជ** ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៣ និង៣០នាទី នៅចំណុចផ្លូវ ៣០ម៉ែត្រ ស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណី ឆក់យកកាបូបលុយ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ហៅ **អាធី** ភេទប្រុស អាយុ២៥ឆ្នាំ និងបក្ខពួកមិនស្គាល់ឈ្មោះ ភេទប្រុស បើកម៉ូតូម៉ាក HONDA សេ-១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ១IV-៨៣១៣ ទៅអែមនឹងម៉ូតូកង់បី PASS APP ដែលជនរងគ្រោះឈ្មោះ [redacted] **សម្ភស្ស** ជិះ ហើយជនរងគ្រោះដោះកាបូបលុយក្រវ៉ាត់នៅចង្កេះមកកាន់ ទន្ទឹមនោះដែរ ជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ក៏ឆក់កាបូបពីជនរងគ្រោះ និងប្រតាយប្រតប់អូសជនរងគ្រោះបណ្តាលឱ្យជនរងគ្រោះរងរបួស ទើបជនជាប់ចោទដួលម៉ូតូ និងយកកាបូបរបស់ជនរងគ្រោះរត់ឡើងជិះម៉ូតូជាបក្ខពួករបស់ខ្លួន ដែលជិះបិទគូថជិះគេចខ្លួនបាត់ ។ ជនជាប់ចោទបានបន្សល់ទុកម៉ូតូម៉ាក ហុងដា សេ-១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ១IV-៨៣១៣ ដែលជិះធ្វើសកម្មភាពនោះនៅនឹងកន្លែងកើតហេតុ ។ សមត្ថកិច្ចបានកសាងសំណុំរឿង រួមទាំងវត្ថុតាងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ឆ្លើយថា៖ ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់ ។ ខ្លួនទទួលស្គាល់ថាម៉ូតូដែលជិះយកទៅឆក់នោះជាម៉ូតូរបស់ខ្លួនពិតប្រាកដមែន ព្រោះម៉ូតូនោះពួកម៉ាកខ្លួនបានខ្ចីពីខ្លួនទៅ ហើយវាទៅឆក់គេដោយខ្លួនពុំបានដឹងទេ ។ ពួកម៉ាកខ្លួននោះឈ្មោះ **ឌី** ស្គាល់គ្នានៅកន្លែងលេងបាល់ តែខ្លួនមិនស្គាល់សាវតាវាទេ ។ វាខ្ចីម៉ូតូខ្លួនថាយកទៅទិញសាច់ថ្លែមព្រោះពេលនោះខ្លួនកំពុងរៀបចំផឹកជាមួយវា ។ ពេលបាត់វាយូរពេកខ្លួនបានដើររកវាតែមិនឃើញ ខ្លួនបានទូរស័ព្ទប្រាប់ប្រពន្ធខ្លួនដើម្បីមកជួយរកម៉ូតូ ពេលប្រពន្ធខ្លួនមកដល់ក៏បានដើររកម៉ូតូជាមួយគ្នា ។ ខ្លួនមិនបានទៅរាយការប្រាប់សមត្ថកិច្ចទេ ព្រោះគិតថាខ្លាចមានការពាក់ព័ន្ធ ។ បីបួនថ្ងៃក្រោយមកទើបខ្លួនដឹងថាអ្នកខ្ចីម៉ូតូរបស់ខ្លួននោះយកម៉ូតូរបស់ខ្លួនជិះទៅឆក់គេ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សម្ភស្ស** ឆ្លើយថា៖ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៣ និង៣០នាទី ខ្លួនយកប្រាក់ទៅដាក់កន្លែងវីង នៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ ពេលខ្លួនដោះកាបូបលុយពីចង្កេះស្រាប់តែបុរសម្នាក់អាយុប្រហែល ២៥ឆ្នាំ ជិះម៉ូតូម៉ាកហុងដាឌ្រីម ស-១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ១IV-៨៣១៣ បានឆក់យកកាបូបរបស់ខ្លួនតែម្តង ។ ក្នុងកាបូបនោះមានលុយចំនួន ១.៥០០ (មួយពាន់ប្រាំ) ដុល្លារអាមេរិក ដែលខ្លួនបំរុងយកទៅដាក់វីង ។ ពេលឆក់នោះខ្លួនបានប្រតាយ

ទាញម៉ូតូចោរ ហើយចោរបានអូសខ្លួនប្រហែលបីម៉ែត្រទើបម៉ូតូចោរដួល ហើយចោរនោះកាន់កាបូបលុយរត់ឡើងជិះម៉ូតូគ្នាវាគេចខ្លួនទៅបាត់ ដោយទុកម៉ូតូដែលវាជិះធ្វើសកម្មភាពខាងលើចោលនៅកន្លែងកើតហេតុ ។ ខ្លួនស្គាល់មុខចោរនោះច្បាស់ ព្រោះប្រតាយប្រតប់គ្នា ។ ឈ្មោះ [redacted] ពន្លី ដែលឈរក្នុងសវនាការពេលនេះគឺពិតជាចោរដែលបានឆក់កាបូបរបស់ខ្លួននោះពិតប្រាកដ ។ ខ្លួនប្ដឹងទាមទារប្រាក់ខ្លួនចំនួន ១.៥០០ ដុល្លារអាមេរិក និងទាមទារជម្ងឺចិត្តចំនួន ១.៥០០ ដុល្លារអាមេរិក ពីជនជាប់ចោទ ។

-ប្រពន្ធរបស់ជនជាប់ចោទបានឆ្លើយថា: ថ្ងៃកើតហេតុប្ដីរបស់ខ្លួនបានទូរស័ព្ទហៅខ្លួនមកជួយរកម៉ូតូ ដោយគាត់ប្រាប់ថាម៉ូតូត្រូវគេខ្ចីហើយយកទៅបាត់តែម្ដង ។ ពួកខ្លួនមិនបានប្ដឹងសមត្ថកិច្ចទេ ដោយមិនហ៊ានទៅប្ដឹងព្រោះកាតគ្រីម៉ូតូដាក់បញ្ចាំនៅធនាគារ ។

-សាក្សីឈ្មោះ [redacted] ឡៃឈឹង អវត្តមានតាមកំណត់ហេតុចម្លើយនៅសមត្ថកិច្ចបានបញ្ជាក់ថា: កាលពីថ្ងៃ១១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៣និង០០នាទី ខ្លួនកំពុងតែជួសជុលរថយន្តនៅក្នុងយានដ្ឋានរបស់ខ្លួនស្ថិតនៅខាងមុខផ្សារសុភមង្គល ផ្លូវ៣០ម៉ែត ភូមិស្រែជិរៅ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ស្រាប់តែឃើញមានមនុស្ស ០២នាក់ប្ដី-ប្រពន្ធ បានជិះម៉ូតូកង់បី PassApp ០១គ្រឿង ពណ៌ស មិនចាំស្លាកលេខ ចូលមកលាងសំអាតនៅកន្លែងយានដ្ឋានជួសជុលរថយន្តរបស់ខ្លួន បានមួយសន្ទុះក្រោយមកស្ត្រីជាប្រពន្ធបានដើរចេញទៅកន្លែងវឹងវេរប្រាក់ នៅខាងមុខផ្សារសុភមង្គល បន្តិចក្រោយមកខ្លួនបានឮសំលេងមានគេស្រែកឆោឡោថាចោរៗ ទើបខ្លួនចេញពីក្នុងយានដ្ឋានជួសជុលរថយន្ត និងលាង រថយន្ត-ម៉ូតូ ក៏ឃើញស្ត្រីជាប្រពន្ធរបស់ម្ចាស់ម៉ូតូកង់បី Pass App ០១គ្រឿង ពណ៌ស ដែលចូលលាងសំអាតម៉ូតូ នៅកន្លែងខ្លួននោះកំពុងតែចាប់ទាញកាងម៉ូតូ ០១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ សេរី២០២១ ពាក់ស្លាកលេខភ្នំពេញ 1IV-8313 ពីខាងក្រោយ ដែលឃើញមានជនជាប់ចោទកំពុងជិះគេចខ្លួន ពេលនោះជនជាប់ចោទដែលជិះម៉ូតូគេចខ្លួននោះ បានដួលម៉ូតូនៅក្បែរនោះ រួចហើយជនជាប់ចោទ បានស្ទុះដើររត់ទៅឡើងជិះលើម៉ូតូរបស់បក្ខពួកវាម្នាក់ទៀតដែលជិះម៉ូតូ ០១គ្រឿង ទៀត មិនចាំម៉ាកចាំបិទគូទ ហើយនាំគ្នាជិះម៉ូតូគេចខ្លួនចេញពីកន្លែងកើតហេតុបាត់ដោយបន្សល់ទុកម៉ូតូ ០១គ្រឿង ម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ សេរី២០២១ លេខតួ-លេខម៉ាស៊ីន 6031880 ពាក់ស្លាកលេខ ភ្នំពេញ 1IV-8313 (ជាមធ្យោបាយរបស់ជនសង្ស័យ) ជិះធ្វើសកម្មភាពឆក់កាបូបស្ពាយពីជនរងគ្រោះដួលនៅកន្លែងកើតហេតុ ។

-ក្រឡាបញ្ជីអានលិខិតព័ត៌មានរបស់មន្ត្រីនគរបាលយុត្តិធម៌, របាយការណ៍សំយោគ, កំណត់ហេតុពិនិត្យកន្លែងកើតហេតុបញ្ជាក់ថា: ឈ្មោះ [redacted] ពន្លី ហៅ អាធី ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តសកម្មភាព **លួចមានស្ថានទម្ងន់ទោស** នៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ពិតប្រាកដមែន ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យកលេខ **១៧៣២ រ.វ.ត** ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ បានពិនិត្យភិនភាគវត្ថុចាប់យកដែលទាក់ទិនក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ **៩៩៨២** ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទឈ្មោះ [redacted] ពន្លី ហៅ អាធី ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួមសរសេរថា: ម៉ូតូចំនួន ០១គ្រឿង ម៉ាក HONDA DREAM ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ ១IV-៨៣១៣ **(មិនប្រក្រតី)** ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

នៅពេលសួរដេញដោលនាពេលសវនាការរួចមកឃើញថាជនជាប់ចោទឈ្មោះ [redacted] ពន្លី ហៅ អាធី ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ បានព្យាយាមបដិសេធមិនសារភាពថាបានប្រព្រឹត្តដូចតាមការចោទប្រកាន់នោះឡើយ តែជនជាប់



Scanned with CamScanner

ចោទរូបនេះពុំមានភស្តុតាងណាសម្រាប់ដោះបន្ទុកឱ្យខ្លួនទេ ផ្ទុយទៅវិញជនរងគ្រោះបានចង្អុលបង្ហាញយ៉ាងច្បាស់ក្នុងពេលសវនាការនេះថាពិតជាជនជាប់ចោទរូបនេះយ៉ាងពិតប្រាកដជាអ្នកឆក់កាបូបលុយរបស់គាត់ ដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ **៤២៩៥** អ.យ.ឋ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ទាំងស្រុងសូមលោកចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា: កូនក្តីខ្ញុំបានបញ្ជាក់ច្បាស់ថាគាត់មិនបានប្រព្រឹត្តដូចតាមការចោទប្រកាន់ទេ ។ ម៉ូតូគាត់ត្រូវបានឈ្មោះ **តី** ខ្ចីទៅទិញសាច់ក្អែម ហើយយកទៅបាត់តែម្តង ។ ប្រពន្ធរបស់ជនជាប់ចោទក៏បានមកឆ្លើយក្នុងសវនាការនេះដែរថាថ្ងៃនោះគាត់បានមកជួករកម៉ូតូនេះដែរ ។ ដូច្នេះបញ្ជាក់បានថាកូនក្តីខ្ញុំពុំបានឆក់កាបូបគេដូចតាមការចោទប្រកាន់នោះឡើយ ។ ខ្ញុំសំណូមពរឱ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទ ។

-ជនជាប់ចោទបាននិយាយសម្តីចុងក្រោយថា: សូមតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់ចម្លើយសាក្សី ។

-ក្រោយពីបានស្តាប់តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន ។

-ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងរាជធានីភ្នំពេញ
## យល់ឃើញថា

១-តាមដីកាសន្និដ្ឋានស្ថាពរលេខ **៤២៩៥** អ.យ.ឋ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា: កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៣ និង៣០នាទី នៅចំណុចផ្លូវ ៣០ម៉ែត្រ ស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណី ឆក់យកកាបូបលុយបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ហៅ **អាធី** ភេទប្រុស អាយុ២៥ឆ្នាំ និងបក្ខពួកមិនស្គាល់ឈ្មោះ ភេទប្រុស បើកម៉ូតូម៉ាក HONDA សេ-១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ១IV-៨៣១៣ ទៅអែមនឹងម៉ូតូកង់បី PASS APP ដែលជនរងគ្រោះឈ្មោះ [redacted] **សម្ភស្ស** ជិះ ហើយជនរងគ្រោះដោះកាបូបលុយក្រវ៉ាត់នៅចង្កេះមកកាន់ ទន្ទឹមនោះដែរជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ក៏ឆក់កាបូបពីជនរងគ្រោះ និងប្រតាយប្រតបអូសជនរងគ្រោះបណ្តាលឱ្យជនរងគ្រោះរងរបួស ទើបជនជាប់ចោទដួលម៉ូតូ និងយកកាបូបរបស់ជនរងគ្រោះរត់ឡើងជិះម៉ូតូជាបក្ខពួករបស់ខ្លួន ដែលជិះបិទគូថជិះគេចខ្លួនបាត់ ។ ជនជាប់ចោទបានបន្សល់ទុកម៉ូតូម៉ាក ហុងដា សេ-១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ១IV-៨៣១៣ ដែលជិះធ្វើសកម្មភាពនោះនៅនឹងកន្លែងកើតហេតុ ។ សមត្ថកិច្ចបានកសាងសំណុំរឿង រួមទាំងវត្ថុតាងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ថា: ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់ ។ ខ្លួនទទួលស្គាល់ថាម៉ូតូដែលជិះយកទៅឆក់នោះជាម៉ូតូរបស់ខ្លួនពិតប្រាកដមែន ព្រោះម៉ូតូនោះពួកម៉ាកខ្លួនបានខ្ចីពីខ្លួនទៅ ហើយវាទៅឆក់គេដោយខ្លួនពុំបានដឹងទេ ។ ពួកម៉ាកខ្លួននោះឈ្មោះ **តី** ស្គាល់គ្នានៅកន្លែងលេងបាល់ តែខ្លួនមិនស្គាល់សារពាវាទេ ។ វាខ្ចីម៉ូតូខ្លួនថាយកទៅទិញសាច់ក្អែមព្រោះពេលនោះខ្លួនកំពុងរៀបចំផឹកជាមួយវា ។ ពេលបាត់វាយូរពេកខ្លួនបានដើររកវាតែ



Scanned with CamScanner

មិនឃើញ ខ្លួនបានទូរស័ព្ទប្រាប់ប្រពន្ធខ្លួនដើម្បីមកជួយរកម៉ូតូ ពេលប្រពន្ធខ្លួនមកដល់ក៏បានដើររកម៉ូតូជាមួយគ្នា ។ ខ្លួនមិនបានទៅរាយការប្រាប់សមត្ថកិច្ចទេព្រោះគិតថាខ្លាចមានការពាក់ព័ន្ធ ។ បីបួនថ្ងៃក្រោយមកទើបខ្លួនដឹងថាអ្នកខ្ចីម៉ូតូរបស់ខ្លួននោះយកម៉ូតូរបស់ខ្លួនជិះទៅឆក់គេ ។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សម្ភស្ស** បានបញ្ជាក់ថា: ខ្លួនស្គាល់មុខចោរនោះច្បាស់ ព្រោះបានប្រតាយប្រតប់គ្នា ។ ឈ្មោះ [redacted] **ពន្លឺ** ដែលឈរក្នុងសវនាការពេលនេះគឺពិតជាចោរដែលបានឆក់កាបូបរបស់ខ្លួននោះពិតប្រាកដ ។

៤-តាមចម្លើយរបស់ប្រពន្ធជនជាប់ចោទថា: ថ្ងៃកើតហេតុប្តីរបស់ខ្លួនបានទូរស័ព្ទហៅខ្លួនមកជួយរកម៉ូតូ ដោយគាត់ប្រាប់ថាម៉ូតូត្រូវគេខ្ចីហើយយកទៅបាត់តែម្តង ។ ពួកខ្លួនមិនបានប្តឹងសមត្ថកិច្ចទេ ដោយមិនហ៊ានទៅប្តឹងព្រោះកាតគ្រីម៉ូតូដាក់បញ្ចាំនៅធនាគារ ។

៥-តាមចម្លើយសាក្សីឈ្មោះ [redacted] **ឡៃឈីង** ថា: កាលពីថ្ងៃ១១ ខែ សីហា ឆ្នាំ២០២២ វេលាម៉ោង ១៣និង០០នាទី ខ្លួនកំពុងតែជូសជុលរថយន្តនៅក្នុងយានដ្ឋានរបស់ខ្លួនស្ថិតនៅខាងមុខ ផ្សារសុភមង្គល ផ្លូវ៣០ម៉ែត ភូមិស្រែជំរៅ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះក៏ឃើញ មានមនុស្ស ០២នាក់ ប្តី-ប្រពន្ធ បានជិះម៉ូតូកង់បី PassApp ០១គ្រឿង ពណ៌ស មិនចាំស្លាកលេខ ចូលមកលាងសំអាតនៅកន្លែងយានដ្ឋានជួសជុលរថយន្តរបស់ខ្លួនបានមួយសន្ទុះក្រោយមកស្ត្រីជាប្រពន្ធបានដើរចេញទៅកន្លែងវីងវេរប្រាក់នៅខាងមុខផ្សារសុភមង្គល បន្តិចក្រោយមកខ្លួនបានឮសំលេងមានគេស្រែកឆោឡោថាចោរៗ ទើបខ្លួនចេញពីក្នុងយានដ្ឋានជួសជុលរថយន្ត និងលាង រថយន្ត-ម៉ូតូ ក៏ឃើញស្ត្រីជាប្រពន្ធរបស់ម្ចាស់ម៉ូតូកង់បីដែលចូលលាងសំអាតម៉ូតូនៅកន្លែងខ្លួននោះកំពុងតែចាប់ទាញកាងម៉ូតូ ០១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ សេរី២០២១ ពាក់ស្លាកលេខភ្នំពេញ 1IV-8313 ពីខាងក្រោយ ដែលឃើញមានជនជាប់ចោទកំពុងជិះគេចខ្លួន ពេលនោះជនជាប់ចោទដែលជិះម៉ូតូគេចខ្លួននោះបានដួលម៉ូតូនៅក្បែរនោះ រួចហើយជនជាប់ចោទ បានស្ទុះងើបរត់ទៅឡើងជិះលើម៉ូតូរបស់បក្ខពួកវាម្នាក់ទៀតដែលជិះម៉ូតូ ០១គ្រឿងទៀត មិនចាំម៉ាកចាំបិទគូទ ហើយនាំគ្នាជិះម៉ូតូគេចខ្លួនចេញពីកន្លែងកើតហេតុបាត់ដោយ បន្សល់ទុកម៉ូតូ ០១គ្រឿង ម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ សេរី២០២១ លេខតួ-លេខម៉ាស៊ីន 6031880 ពាក់ស្លាក លេខ ភ្នំពេញ 1IV-8313 (ជាមធ្យោបាយរបស់ជនសង្ស័យ) ជិះធ្វើសកម្មភាពឆក់កាបូបស្ពាយពីជនរងគ្រោះដួលនៅកន្លែងកើតហេតុ ។

៦-ផ្អែកតាមរបាយការណ៍សំយោគលេខ **០១៨/២២ រ.ប.ក** ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ បានសន្និដ្ឋានថា: ឈ្មោះ [redacted] **ពន្លឺ** ហៅ **អាធី** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តសកម្មភាព **លួចមានស្ថានទម្ងន់ទោស** នៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ពិតប្រាកដមែន ។

៧-តាមចម្លើយជនជាប់ចោទដែលបានឆ្លើយដោះសារ តែពុំមានភស្តុតាងណាដើម្បីដោះបន្ទុកនោះឡើយ ផ្ទុយទៅវិញផ្អែកតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី និងរបាយការណ៍សំយោគលេខ ០១៨/២២ រ.ប.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ មានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថាជនជាប់ចោទពិតជាបានប្រព្រឹត្តសកម្មភាព **លួចមានស្ថានទម្ងន់ទោស(ឆក់កាបូប)** នៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២២ ពិតប្រាកដមែន ។

៨-វត្ថុចាប់យកមាន ម៉ូតូចំនួន ០១គ្រឿង ម៉ាក HONDA DREAM ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ ១IV-៨៣១៣ **(មិនប្រក្រតី)** គប្បីរឹបអូស ។

៩-ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារប្រាក់ចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក និងទាមទារជម្ងឺចិត្ត ចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក **គប្បីគុណាការលើកមកពិចារណា** ។

១០-ជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ហៅ **អាជី** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ជានីតិជន ដែលមានសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានបញ្ហាស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសទេ ហើយជននេះជាមនុស្សដែលមានការពិចារណាយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវចំពោះមុខច្បាប់ ។

១១-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ដែលច្បាប់បានកំណត់ ។

១២-មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **ពន្លឺ** ហៅ **អាជី** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៧** នៃ **ក្រមព្រហ្មទណ្ឌ** ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] **ពន្លឺ** ហៅ **អាជី** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ **(បួន) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៧** នៃ **ក្រមព្រហ្មទណ្ឌ** ។

២-ឱ្យឈ្មោះ [redacted] **ពន្លឺ** ហៅ **អាជី** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

៣-វត្ថុចាប់យកមាន ម៉ូតូចំនួន ០១គ្រឿង ម៉ាក HONDA DREAM ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ ១IV-៨៣១៣ **(មិនប្រក្រតី) រឹបអូស** ។

-សាលក្រមជំនុំជម្រះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា និងត្រា: [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃពុធ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner